ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
******

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
******

**ជំនួបរវាងឯកឧត្តម ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**
**និងលោកស្រី Setsuko Yamazaki, នាយិកាអង្គការ UNDP**

******

នៅរសៀលថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០១៦ វេលាម៉ោង១៦:០០នាទី នៅទីស្តីការក្រសួង ឯកឧត្តម **ប្រាក់ សុខុន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតឱ្យលោកស្រី **Setsuko Yamazaki** នាយិកាអង្គការ UNDP ប្រចាំនៅកម្ពុជា( UNDP Country Director ) ចូលជួបជម្រាបលា ក្នុងឱកាសដែលលោកស្រីបានបញ្ចប់បេសកកម្មការងារនៅកម្ពុជា។

នៅក្នុងជំនួបនេះ ឯកឧត្តមទេសរដ្ឋមន្ត្រី **ប្រាក់ សុខុន** បានសំដែងនូវការរីករាយ និងការពេញចិត្តចំពោះទំនាក់ទំនងជាដៃគូដ៏ខ្លាំងរឹងមាំ និងជិតស្និទ្ធរវាងអង្គការ UNDP និងរាជរដ្ឋាភិបាលកម្ពុជា ក្នុងការកសាងនិងអភិវឌ្ឍន៍ប្រទេសកម្ពុជាលើគ្រប់វិស័យ ពិសេសគឺការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍធនធានមនុស្ស ហើយនិងការជួយរបស់អង្គការUNDPដល់កម្ពុជា ដើម្បីសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍របស់កម្ពុជា ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានវាយតំលៃខ្ពស់ ចំពោះការជួយឧបត្ថម្ភគ្រប់បែបយ៉ាងរបស់អង្គការ UNDP ហើយនិងការរួមចំណែកដោយផ្ទាល់ និងដ៏សកម្មរបស់លោកស្រីនាយិកា ក្នុងការជួយដល់កម្ពុជា ។

លោកស្រី Setsuko Yamazaki បានលើកឡើងនូវការចាប់អារម្មណ៍ និងការកោតសរសើររបស់លោកស្រី ចំពោះការអភិវឌ្ឍលើគ្រប់វិស័យយ៉ាងឆាប់រហ័សនៅកម្ពុជា ដែលលោកស្រី បានសង្កត់ធ្ងន់ជាពិសេសទៅលើការវិវត្តន៍ប្រែប្រួលរបស់កម្ពុជា ពីស្ថានភាពជាប្រទេសដែលត្រូវបានបំផ្លិចបំផ្លាញខ្ទេចខ្ទាំដោយសង្គ្រាម មកជាប្រទេសប្រកបដោយសន្តិភាពពេញលេញ និងការរីកចម្រើនយ៉ាងលឿន ។

លោកស្រីនាយិកា បានវាយតំលៃខ្ពស់ពីទំនាក់ទំនងដ៏ល្អ និងជិតស្និទ្ធរវាងកម្ពុជា និងអង្គការ UNDP ហើយនិងការខិតខំរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការសម្រេចនូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍របស់ខ្លួន។

លោកស្រីនាយិកា បានវាយតំលៃខ្ពស់ចំពោះការយកចិត្តទុកដាក់ និងការខិតខំរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី **ប្រាក់ សុខុន** ក្នុងពេលដែល**ឯកឧត្តម**ជាអនុប្រធានទី១ នៃអាជ្ញាធរកម្ពុជាគ្រប់គ្រង

សកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ក្នុងប្រតិបត្តិការបោសសំអាតមីន ក៏ដូចជាក្នុងការកសាងនិងពង្រឹងនូវកិច្ចសហប្រតិបត្តិការ ជាមួយដៃគូអន្តរជាតិ ក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តមនេះ។

លោកស្រី បានគូសបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់អង្គការ UNDP ក្នុងការជួយដល់កម្ពុជា ដើម្បីឈានទៅរកកំរិតមួយទៀត នៃការអភិវឌ្ឍន៍របស់ប្រទេសជាតិ និងអំពីបំណងរបស់អង្គការUNDP ក្នុងការបន្តកិច្ចសហការជាមួយកម្ពុជា និងក្នុងការផ្តល់ជាគំនិត និងបទពិសោធន៍ ដើម្បីជួយកម្ពុជាសម្រេចឱ្យបាននូវគោលបំណងនៃការប្រែក្លាយខ្លួន ពីប្រទេសដែលទទួលជំនួយ ទៅជាដៃគូធុរកិច្ច និងសេដ្ឋកិច្ចរបស់សហគមន៍អន្តរជាតិ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានជំរាបជូនលោកស្រីនាយិកា អំពីការជំរុញរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ក្នុងការខិតខំប្រឹងប្រែងដើម្បីប្រែក្លាយកម្ពុជាពីប្រទេស ដែលទទួលជំនួយទៅជាប្រទេសដៃគូសេដ្ឋកិច្ចរបស់សហគមន៍អន្តរជាតិ ។ **ឯកឧត្តម** ក៏បានសម្តែងការស្វាគមន៍ចំពោះការផ្តល់ជាគំនិត និងបទពិសោធន៍របស់អង្គការUNDP ដើម្បីជួយកម្ពុជាសម្រេចបានគោលដៅខាងលើនេះ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានជំរាបជូនលោកស្រីនាយិកាថា ក្រសួងការបរទេស នឹងបន្តនូវកិច្ចសហប្រតិបត្តិការដ៏ល្អប្រសើររវាងកម្ពុជា និងអង្គការ UNDP ហើយនិងបន្តកិច្ចសហប្រតិបត្តិការនេះ ជាមួយនឹងនាយក/នាយិកាអង្គការ UNDP ថ្មី ដែលមកជំនួសលោកស្រី។

ជំនួបនេះ បានបញ្ចប់ក្នុងបរិយាកាសរីករាយ និងស្និទ្ធស្នាលក្រៃលែង។

ភ្នំពេញ ថ្ងៃទី ២១ ខែតុលា ឆ្នាំ២០១៦